បុព្វកថានៃសេចក្ដីប្រកាសឯករាជ្យ

ក្នុងសភាកាលពីថ្ងៃទី៤ ខែកក្កដា ឆ្នាំ១៧៧៦



IN CONGRESS, JULY 4, 1776.

A DECLARATION

BY THE REPRESENTATIVES OF THE

UNITED STATES OF AMERICA,

IN GENERAL CONGRESS ASSEMBLED.

WHEN in the Course of human Events, it becomes necessary for one People to dissolve the Political Bands which have connected them with another, and to assume among the Powers of the Earth, the separate and equal Station to which the Laws of Nature and of Nature's God entitle them, a decent Respect to the Opinions of Mankind requires that they should declare the causes which impel them to the Separation.

រូបភាពខាងលើនេះគឺជាការចោះពុម្ពទីមួយដ៏កម្រនៃសេចក្ដីប្រកាសឯករាជ្យ។ ឯកសារច្បាប់ដើមសរសេរដោយដៃនេះ ត្រូវដាក់តាំងបង្ហាញជាអចិន្ត្រៃយ៍នៅបណ្ណសារជាតិនៅរដ្ឋធានីវ៉ាស៊ីនតោន។ រូបភាពAP

សេចក្ដីប្រកាសជាឯកច្ឆន្ទពីរដ្ឋទាំង១៣របស់អាមេរិក

ពេលណា ក្នុងការវិវត្តន៍នៃព្រឹត្តិការណ៍របស់មនុស្ស លោក មានការចាំបាច់ដើម្បីរំលាយចំណងនយោបាយ ដែលផ្សារភ្ជាប់ពួកគេ ពីក្រុមមួយ ទៅក្រុមមួយទៀត ហើយទទួលបានពីប្រទេស ដែលមានអធិបតេយ្យភាពឯទៀតនូវឋានៈដោយឡែកនឹងមានសមភាព ដែលគេត្រូវបានទទួលពីច្បាប់ធម្មជាតិនិងពីព្រះជាម្ចាស់ សេចក្ដីគោរពដ៏សមរម្យមួយដែលត្រូវមានដល់មតិរបស់មនុស្សជាតិ តម្រូវឲ្យពួកគេប្រកាសបុព្វហេតុនានា ដែលជំរុញពួកគេឲ្យបែកពីគ្នា។ យើងចាត់ថា ការណ៍ពិតដ៏ប្រត្យក្ស ដែលថា មនុស្សយើងទាំងអស់កើតមកមានឋានៈស្មើៗគ្នាថា ពួកគេត្រូវបានព្រះជាម្ចាស់ផ្ដល់ឲ្យនូវសិទ្ធិ ដែលមិនអាចប្រកែកបាន ក្នុងនោះមានអាយុជីវិត សិទ្ធិសេរីភាព និង ការស្វែងរកសុភមង្គល ដែលថា ដើម្បីរក្សាសិទ្ធិទាំងនេះ ឲ្យបានគង់វង់ រដ្ឋាភិបាលត្រូវបានបង្កើតឡើង ហើយទាញយកអំណាចដ៏សមស្រប និង ទទួលការយល់ព្រមពីប្រជាជនដែលគេគ្រប់គ្រង ហើយថា នៅពេលណាដែលរដ្ឋាភិបាលណាមួយធ្វើឲ្យខូចដល់គោលដៅ ដែលការពារជីវិត សេរីភាពនិងការស្វែងរកសុភមង្គលរបស់ពួកគេ ពួកគេមានសិទ្ធិផ្លាស់ប្ដូរ ឬរំលាយរដ្ឋាភិបាលនោះ ហើយបង្កើតរដ្ឋាភិបាលថ្មី ដែលមានមូលដ្ឋានរៀបចំលើគោលការណ៍បែបនេះ ហើយរៀបចំអំណាចរបស់ខ្លួនដើម្បីសុវត្ថិភាព និង សុភមង្គលរបស់គេ។

លោក Thomas Jefferson ធ្វើសេចក្ដីព្រាងទីមួយនៃសេចក្ដីប្រកាសឯករាជ្យ។ រូបភាព*AP*